01667502

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

## អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារ D266/28 និង D267/36

***តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ***

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ៣៥)

**<u>អង្គបុរេជំនុំជម្រះ</u>**

| | |
|---|---|
| ចំពោះមុខ: | **ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន** |
| | **ចៅក្រម Olivier BEAUVALLET** |
| | **ចៅក្រម នីយ ថុល** |
| | **ចៅក្រម Kang Jin BAIK** |
| | **ចៅក្រម ហួត វុទ្ធី** |
| កាលបរិច្ឆេទ: | **ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១** |

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 08-Apr-2021, 10:30
CMS/CFO: Sann Rada

---

**សាធារណៈ**

**សេចក្តីសម្រេចលើការធ្វើចំណាត់ប្រភេទឯកសារឡើងវិញរបស់អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង ០០៣**

---

**<u>សហព្រះរាជអាជ្ញា៖</u>**

ជា លាង

Brenda J. HOLLIS

**<u>សហមេធាវីការពារក្តី យឹម ទិត្យ៖</u>**

អាង ឧត្តម

Michael G. KARNAVAS

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី</u>**

ហុង គឹមសួន
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉េន ពៅ
Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN- NZEPA

Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**រម្លឹកឡើងវិញ** នូវ "សេចក្ដីសម្រេចលើការធ្វើចំណាត់ប្រភេទឯកសារឡើងវិញរបស់អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង ០០៣" ដែលបានចេញនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលអង្គបុរេជំនុំជម្រះបានសម្រេចថា អង្គជំនុំជម្រះនឹងចេញសេចក្ដីសម្រេចលើការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ០០៣ ក្រោយពីចេញសាលដីការបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣[1]

**កត់សម្គាល់ឃើញ** ថា អង្គជំនុំជម្រះបានចេញសេចក្ដីពិចារណាជាសាធារណៈរបស់ខ្លួន លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៣ នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១[2]

**កត់សម្គាល់ឃើញ** ថា អង្គបុរេជំនុំជម្រះកំពុងពិនិត្យសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចស្ដីពីភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[3]

**កត់សម្គាល់ឃើញ** ថា អនុលោមតាមមាត្រា ៩(១) នៃសេចក្ដីណែនាំអនុវត្តស្ដីអំពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង ឯកសារអាចធ្វើចំណាត់ប្រភេទ និងកំណត់កម្រិតនៃការសម្ងាត់ខុសគ្នាចំពោះផ្នែកណាមួយនៃសំណុំរឿង អនុលោមតាមទៅតាមដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ តាមករណីសមស្រប តែប៉ុណ្ណោះ។

---

[1] សំណុំរឿង ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៣") (អ.ប.ជ ៣៥) សេចក្ដីសម្រេចលើការធ្វើចំណាត់ប្រភេទឯកសារឡើងវិញរបស់អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ ឯកសារ D266/26 និង D267/34។

[2] សំណុំរឿង ០០៣ (អបជ៣៥) សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ ឯកសារ D266/27 & D267/35។

[3] សំណុំរឿង ០០៣ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាស្ដីពីភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ បានជូនដំណឹងជាភាសាខ្មែរនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D269/3។

01667504



**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះ យោងតាមសម្លេងឯកច្ឆ័ន្ទ៖**

**បង្គាប់** ឱ្យមន្ត្រីគ្រប់គ្រងសំណុំរឿងនៃផ្នែកគ្រប់គ្រងតុលាការ ធ្វើចំណាត់ប្រភេទឯកសារឡើងវិញដែលមានរៀបរាប់នៅក្នុងឧបសម្ពន្ធភ្ជាប់ជាមួយសេចក្តីសម្រេចនេះ ពីឯកសារ "សម្ងាត់" / "កោសលុបជាសាធារណៈ" ទៅជាឯកសារ "សាធារណៈ" វិញ។

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន័យ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**